ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

លេខ ៦១០៣៥...សផស

# របាយការណ៍
# ស្ដីពី
# សកម្មភាពការងារសុខភាពសត្វ និងផលិតកម្មសត្វ
# (ប្រចាំឆមាសទី១ ឆ្នាំ២០២០)

**កម្មវត្ថុ៖** របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២០ ដោយគិតពីថ្ងៃទី១៦/១២/១៩-១៥/០៦/២០ ស្ដីពីសកម្មភាពការងារវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

## I. ការងារនាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ

### ១- ការងាររដ្ឋបាល និងបុគ្គលិក

#### ក.ការងាររៀបចំលិខិតស្នាម

រៀបចំលិខិតចេញបានចំនួន២ ១៨១ច្បាប់ ក្នុងនោះមានលិខិតបេសកកម្ម ប្រជុំ និងសិក្ខាសាលាជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ត្រីបានចំនួន៧៧១ច្បាប់ លិខិតអញ្ជើញរាជធានី-ខេត្តបានចំនួន២៣៧ច្បាប់ លិខិតទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចំនួន៣៤៣ច្បាប់ លិខិតទៅអង្គភាពក្រៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៨២៨ច្បាប់ ព្រមទាំងលិខិតចូលទទួលបានចំនួន២ ៩៧២ច្បាប់។

#### ខ.ការងារបុគ្គលិក

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានមន្ត្រីសរុបចំនួន២៩៣នាក់ ក្នុងនោះប្រុសចំនួន២០៥នាក់ និងស្រីចំនួន៨៨នាក់៖

- ក្របខ័ណ្ឌក ចំនួន១៨៣នាក់ ក្នុងនោះប្រុសចំនួន១៣៦នាក់ និងស្រីចំនួន៤៧នាក់៖
  - **ក១**សរុបចំនួន២១នាក់ ក្នុងនោះប្រុសចំនួន១៨នាក់ និងស្រីចំនួន០៣នាក់
  - **ក២**សរុបចំនួន៩៣នាក់ ក្នុងនោះប្រុសចំនួន៧២នាក់ និងស្រីចំនួន២១នាក់
  - **ក៣** សរុបចំនួន៧០នាក់ ក្នុងនោះប្រុសចំនួន៤៧នាក់ និងស្រីចំនួន២៣នាក់។
- ក្របខ័ណ្ឌខ ចំនួន៨៣នាក់ ក្នុងនោះប្រុសចំនួន៤៩នាក់ និងស្រីចំនួន៣៤នាក់៖
  - **ខ១** សរុបចំនួន០១នាក់ ក្នុងនោះប្រុសចំនួន០១នាក់
  - **ខ២** សរុបចំនួន៥៩នាក់ ក្នុងនោះប្រុសចំនួន៣៤នាក់ និងស្រីចំនួន២៥នាក់
  - **ខ៣** សរុបចំនួន២៣នាក់ ក្នុងនោះប្រុសចំនួន១៤នាក់ និងស្រីចំនួន០៩នាក់។
- ក្របខ័ណ្ឌគ ចំនួន២៦នាក់ ក្នុងនោះប្រុសចំនួន១៩នាក់ និងស្រីចំនួន០៧នាក់។
- មន្ត្រីកិច្ចសន្យាសរុប៥០នាក់ ក្នុងនោះស្រី១៩នាក់។

#### គ. ការងាបណ្ដុះបណ្ដាល ប្រជុំ និងសិក្ខាសាលា

**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**- ក្នុងប្រទេស**

- សិក្ខាសាលា និងប្រជុំចំនួន១៣៧លើក
- បណ្ដុះបណ្ដាលចំនួន៣៩លើក។



ភូមិទ្រា ផ្លូវលេខ ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កម្ពុជា
Trea Village, Str. 371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨ ទូរសារ: (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨
Tel.: (855) 23 883 746/884 148 Fax.: (855) 23 883 746/884 148

- **ក្រៅប្រទេស**
  - សិក្ខាសាលា និងប្រជុំចំនួន០៣លើក
  - បណ្តុះបណ្តាលចំនួន០២លើក។

**រាជធានី-ខេត្ត**

- **ក្នុងប្រទេស**
  - សិក្ខាសាលា និងប្រជុំចំនួន១៧០លើក
  - បណ្តុះបណ្តាលចំនួន១ ៥៣៨លើក
  - ទស្សនកិច្ចសិក្សាចំនួន០៣លើក។

**២- ការងារផែនការ និងស្ថិតិ**

- បានបញ្ចប់ការរៀបចំផែនការសកម្មភាព និងថវិកាកម្មវិធីឆ្នាំ២០២០ តាមទម្រង់ P3 & P4 ផ្អែកតាមច្បាប់ថវិកាជាតិឆ្នាំ២០២០ បញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយនាយកដ្ឋាន និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ រៀបចំសេចក្តីព្រាងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ សម្រាប់អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧-២០១៩ នៃគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ធ្វើបច្ចុប្បន្នភាព និងរៀបចំកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល២០២១-២០២៣ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដែលមានគម្រោងសរុបចំនួន០៣គឺ ១.គម្រោងសាងសង់ឡជីវឧស្ម័ន១ ៥០០ឡ បច្ចុប្បន្នកំពុងអនុវត្ត ២.គម្រោងកែលម្អសេនេទិកគោ ផលិតកម្មសត្វ គុណភាពចំណីសត្វ (ការបង្កើតមជ្ឈមណ្ឌលសិប្បនិម្មិតគោទឹកដោះ និងមន្ទីរពិសោធន៍ចំណីសត្វ) ដែលបានស្នើសុំក្នុងឆ្នាំ២០១៩ បច្ចុប្បន្នកំពុងបន្តស្វែងរកជំនួយ ៣.គម្រោងកែលម្អការចិញ្ចឹមសត្វ លើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល ដែលបានស្នើសុំក្នុងឆ្នាំ២០២០ នេះ
- កំពុងធ្វើការបូកសរុបលទ្ធផលការងារសុខភាពសត្វ និងផលិតកម្មសត្វរយៈពេល០៥ឆ្នាំ (២០១៤-២០១៨) សម្រាប់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ឆ្នាំ២០១៩-២០២៣ ឱ្យស្របតាមឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣
- បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បាននឹងកំពុងបន្តរៀបចំបំពេញបន្ថែមសេចក្តីផែនការមេវិស័យកសិកម្ម២០៣០ សម្រាប់អនុវិស័យសុខភាពសត្វ នឹងផលិតកម្មសត្វ
- ចុះពង្រឹងសមត្ថភាព និងបង្កើនប្រសិទ្ធភាពលើការរៀបចំគ្រប់គ្រងទិន្នន័យ និងស្ថិតិរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដល់មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តកំពង់ស្ពឺ ព្រះសីហនុ សៀមរាប បន្ទាយមានជ័យ ព្រៃវែង ស្វាយរៀង មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ ត្បូងឃ្មុំ កំពង់ចាម កំពត កែប កណ្តាល និងខេត្តតាកែវ ដែលមានអ្នកចូលរួមសរុបចំនួន៧៩នាក់ (ស្រី១៥នាក់)
- បូកសរុបទិន្នន័យស្ថិតិសត្វ ជំងឺសត្វ និងព័ត៌មានទាក់ទងសុខភាពសត្វ និងផលិតកម្មសត្វ ដែលទទួលបានពីការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តរៀងរាល់ខែ ឆ្នាំ២០២០។

**៣-ការងារគណនេយ្យ**

- ពិនិត្យកែតម្រូវលើរាល់ឯកសាររដ្ឋទេយ្យបុរេប្រទានតាមផែនការសកម្មភាពនៃកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព សកម្មភាព ដោយទូទាត់បានចំនួន០២ជុំ
- រៀបចំ និងពិនិត្យឯកសារជំរះទូទាត់ទៅតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពរបស់ការិយាល័យជំនាញ ដើម្បីដាក់ស្នើសុំទូទាត់ជាបន្តបន្ទាប់ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



1k

- រៀបចំឯកសារជូនអាជ្ញាធរសវនកម្មជាតិ ពិនិត្យលើការងារអនុវត្តសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ចុះផ្សព្វផ្សាយ និងពង្រឹងការកៀរគរចំណូលពីវិស័យសុខភាពសត្វ និងផលិតកម្មសត្វតាមការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្ត
- ចុះអនុវត្តការងារពង្រឹងការប្រមូលចំណូលពីវិស័យសុខភាពសត្វ និងផលតកម្មសត្វ នៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត បានចំនួន១៧លើក
- បញ្ជូនឯកសារបង្វែរប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រី ទៅធនាគារណាឌីយ៉ា សរុបចំនួន១៨លើក
- សហការ តាមដាន និងជំរុញការពិនិត្យ និងកែតម្រូវឯកសារជាមួយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពន្លឿនការទូទាត់ថវិការដ្ឋទេយ្យបុរេប្រទានតាមកម្មវិធីជុំទី២ វគ្គទី១ ឆ្នាំ២០២០ និងជំរុញការរៀបចំឯកសារទូទាត់ជាបន្តបន្ទាប់ទៀតទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការ និងផ្តល់ថ្នាំការពារ ថ្នាំព្យាបាល សម្ភារបរិក្ខារបសុពេទ្យ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្មសត្វ និងបសុព្យាបាលខេត្ត ដើម្បីចុះអន្តរាគមន៍ពេលមានផ្ទុះជំងឺ
- ផ្តល់ និងផ្គត់ផ្គង់ប្រេងឥន្ធនៈជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីរាជការ ដែលចុះបំពេញបេសកកម្ម
- កត់ត្រាចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វនាំចូល នាំចេញ និងនាំឆ្លងកាត់ (ឧបសម្ព័ន្ធទី១)
- ផ្តល់ប័ណ្ណកម្រៃសេវាកម្ម និងប័ណ្ណសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដោយឥតគិតថ្លៃជូនបណ្តាការិយាល័យផលិតកម្មសត្វ និងបសុព្យាបាលខេត្ត និងរាជធានីមួយចំនួន ដែលបានធ្វើលិខិតស្នើសុំជាផ្លូវការមកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- កត់ត្រាចំណូលពីវិស័យសុខភាពសត្វ និងផលិតកម្មសត្វ (ការនាំចេញ-ចូល) ក្នុងឆមាសទី១ ឆ្នាំ២០២០។

**៤-ការងារសហប្រតិបត្តិការ**

- ពិនិត្យ និងផ្តល់យោបល់លើដីការអមស្តីពីសំណើសុំមន្ត្រីជំនាញចូលរួមកិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យឡើងជាទូទៅនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់យោបល់លើលិខិតរបស់ Swedish proposal to support capacity development on antimicrobial use and resistance in the Cambodian livestock sector
- សម្របសម្រួលរៀបចំលិខិតស្នើសុំចាត់មន្ត្រីទៅចូលរួមកិច្ចប្រជុំស្តីពី Antimicrobial Resistance (AMR) នៅទីក្រុងប៉ារីស ប្រទេសបារាំង
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំការគាំទ្រ និងកិច្ចសហការពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រាប់ការអនុវត្តគម្រោងសិក្សាស្រាវជ្រាវទាក់ទងនឹងជំងឺស៊ុល្លសរបស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំប្រជុំក្រុមការងារ ដើម្បីពិភាក្សាផែនការសហប្រតិបត្តិការ និងកិច្ចប្រជុំទ្វេភាគីលើកទី១០ រវាងកម្ពុជា និងថៃរបស់នាយកដ្ឋានអភិវឌ្ឍន៍បសុសត្វថៃ
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំបន្តកិច្ចសហការរវាងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វជាមួយឧទ្យានរាជបណ្ឌិតសភាតេជោសែនឫស្សីត្រឹបនៃរាជបណ្ឌិតសភាកម្ពុជា
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីប្រកាសរបស់ FAO ស្តីពីការអនុវត្តគម្រោង Strengthening Field Capacities for ASF Detection and Emergency Response
- ពិនិត្យ និងផ្តល់យោបល់លើលិខិតរបស់ស្ថានទូតសហព័ន្ធរុស្សីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាស្តីពី The Veterinary and Sanitary Requirements on the Import of Feed and Feed Additives to the Kingdom of Cambodia

- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំចុះហត្ថលេខាលើ Country Programming Framework 2019-2023 របស់អង្គការ FAO
- សម្របសម្រួលរៀបចំលិខិតស្នើសុំឯកឧត្តមរដ្ឋមន្ត្រីជួយអន្តរាគមន៍ទៅ CDC ដើម្បីនាំចូលធាតុប្រតិករសម្រាប់ប្រើប្រាស់នៅ NAHPRI
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំធ្វើសេចក្តីផ្តល់ព័ត៌មានទៅអង្គការ WTO ស្តីពីការឧបត្ថម្ភគាំទ្រក្នុងស្រុក (Domestic Support) សម្រាប់ឆ្នាំ២០១៨
- សម្របសម្រួលរៀបចំលិខិតឆ្លើយតបលើករណីស្តីពី The Veterinary and Sanitary Requirements on the Import of Feed and Feed Additives to the Kingdom of Cambodia របស់ស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលរៀបចំលិខិតស្នើសុំបញ្ជូនគម្រោងមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងសម្រាប់ឆ្នាំ២០២១ ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលរៀបចំលិខិតចាត់តាំងមន្ត្រីចំនួន១៣រូប នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ASF Online Preparedness របស់អង្គការ FAO
- សម្របសម្រួលរៀបចំលិខិតទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីស្នើសុំការអនុញ្ញាតនាំចូលដោយបង់ពន្ធ និងអាករនូវសម្ភារសម្រាប់ដំឡើងឡជីវឧស្ម័ន។

**៥-ការងារតាមដាន និងវាយតម្លៃ**

- ចុះតាមដានការអនុវត្តអនុកម្មវិធីទី២.៣ ចង្កោមសកម្មភាពទី២ (សកម្មភាពអភិវឌ្ឍន៍សហគមន៍ចិញ្ចឹមសត្វ) របស់នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម នៅខេត្តព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់
- ចុះតាមដានការអនុវត្តអនុកម្មវិធីទី២.៣ ចង្កោមសកម្មភាពទី២ របស់នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម នៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តសៀមរាប
- ចុះតាមដានការអនុវត្តអនុកម្មវិធីទី២.២ ចង្កោមសកម្មភាពទី១និងទី២ របស់នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាលនៅខេត្តឧត្តរមានជ័យ បាត់ដំបង ប៉ៃលិន កំពត និងខេត្តកែប
- ចុះតាមដានការអនុវត្តន៍អនុកម្មវិធីទី២.២ ចង្កោមសកម្មភាពទី១ របស់នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល និងចង្កោមសកម្មភាពទី៣ របស់វិទ្យាស្ថានស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ នៅខេត្តកំពង់ស្ពឺ និងខេត្តតាកែវ
- ចុះតាមដានការអនុវត្តន៍អនុកម្មវិធីទី២.១ ចង្កោមសកម្មភាពទី១ របស់នាយកដ្ឋានផលិតកម្មសត្វ និងអនុកម្មវិធីទី២.៣ ចង្កោមសកម្មភាពទី២ របស់នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនិតិកម្ម នៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ
- ចុះតាមដានការអនុវត្តន៍អនុកម្មវិធីទី២.១ របស់នាយកដ្ឋានផលិតកម្មសត្វ នៅខេត្តបន្ទាយមានជ័យ
- ចុះតាមដានការអនុវត្តន៍អនុកម្មវិធីទី២.៣ ចង្កោមសកម្មភាពទី១ របស់នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នៅខេត្តកោះកុង
- ចុះតាមដានការអនុវត្តន៍អនុកម្មវិធីទី២.២ ចង្កោមសកម្មភាពទី៣ របស់វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និងចង្កោមសកម្មភាពទី១ របស់នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល នៅខេត្តមណ្ឌលគិរី និងខេត្តរតនៈគីរី
- បណ្តុះបណ្តាលជាក់ស្តែងពីការយកសំណាកថនិសត្វតូចដល់ក្រុមការងារពីប្រទេសលាវនៅខេត្តក្រចេះ

- ចូលរួមជាមួយរដ្ឋបាលព្រៃឈើចុះយកសំណាកសត្វប្រជៀវ ជ្រើង ក្នុងគម្រោងសិក្សាហានិភ័យនៃការឆ្លងជំងឺពីសត្វមកមនុស្សដោយថនិសត្វតូច នៅខេត្តកំពត បាត់ដំបង កំពង់ធំ និងខេត្តស្ទឹងត្រែង
- រៀបចំរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍សមិទ្ធកម្មកម្មវិធីប្រចាំឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បូកសរុបរបាយការណ៍តាមដាន និងវាយតម្លៃ (M3) ក្នុងការអនុវត្តសកម្មភាពកម្មវិធីរបស់នាយកដ្ឋានជំនាញ និងវិទ្យាស្ថាន តាមខេត្តគោលដៅសំរាប់ត្រីមាសទី១ និងទី២ ឆ្នាំ២០២០
- រៀបចំសម្របសម្រួលរបាយការណ៍វឌ្ឍនភាពកម្មវិធី និងរបាយការណ៍សមិទ្ធិកម្មប្រចាំត្រីមាសទី១និងទី២ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (M1 & Annex24/25) ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## II.ការងារនាយកដ្ឋានផលិតកម្មសត្វ

### ១-សមិទ្ធផលការងារ

- ចុះវាយតម្លៃទីតាំងស្នើសុំបង្កើតកសិដ្ឋានបានចំនួន២៦កសិដ្ឋាន ក្នុងនោះមានៈ កសិដ្ឋានចិញ្ចឹមជ្រូកពូជ និងមាន់យកសាច់ខ្នាតធំចំនួន០៧កសិដ្ឋាន កសិដ្ឋានចិញ្ចឹមជ្រូកពូជ ជ្រូកសាច់ និងមាន់សាច់ខ្នាតមធ្យមចំនួន០៤កសិដ្ឋាន និងកសិដ្ឋានចិញ្ចឹមជ្រូកសាច់ មាន់ពូជ មាន់ស៊ុត មាន់សាច់ និងគោខ្នាតតូចចំនួន១៥កសិដ្ឋាន
- ចុះពង្រឹងកសិករចិញ្ចឹមសត្វបង្ហាញតាមបទដ្ឋានបច្ចេកទេសនៅខេត្តកំពង់ចាម កំពង់ធំ ត្បូងឃ្មុំ និងខេត្តក្រចេះ
- ចុះសម្រង់វត្ថុធាតុដើមចំណីសត្វនៅក្រុមហ៊ុនម៉ាលីវ៉ាន់ គ្រេឌីង ឯ.ក, Agri-Master, Green Feed Cambodia, Betagro, New Hope, San-Agro, ANT, The Fair, PWR ...
- រៀបចំឯកសារកែលម្អពូជគោឲ្យប្រសើរឡើងតាមរយៈការបង្កាត់ដោយសិប្បនិម្មិត
- ចុះជំរុញការកែលម្អពូជសត្វតាមរយៈការបង្កាត់គោដោយសិប្បនិម្មិតនៅខេត្តកំពង់ចាម
- បាននឹងកំពុងរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ
- ចុះពិនិត្យ និងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយមានមានបញ្ហានៅតាមខេត្តគោលដៅ
- រៀបចំផែនការសម្រាប់អនុវត្តនៅត្រីមាសទី២ ឆ្នាំ២០២០
- ចុះជំរុញការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វស្របតាមប្រកាសលេខ៥៤៩ ប្រក.កសក នៅខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ចាម កំពង់ធំ បាត់ដំបង ព្រះវិហារ ក្រចេះ និងខេត្តត្បូងឃ្មុំ
- ចុះពិនិត្យទីកន្លែងលក់ ផលិត និងលាយផ្សំចំណីសត្វនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង
- ចុះពង្រឹង និងប្រមូលទិន្នន័យសត្វ
- សាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតិចិន នៅតាមខេត្តគោលដៅទាំង០៧ បានចំនួន៣៥ឡ
- បាននឹងកំពុងរៀបចំចងក្រង និងកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមសត្វ និងចំណីសត្វ
- បានរៀបចំសេចក្តីព្រាងត្រួតពិនិត្យ និងវាយតម្លៃកសិដ្ឋានតាមគោលការណ៍ចិញ្ចឹមសត្វល្អ ( *GAHP*)
- រៀបចំឡើងវិញនូវសូចនាករ និងជម្រើសសកម្មភាពអាទិភាពសម្រាប់អនុវត្តន៍ក្នុងឆ្នាំ២០២០
- ស្រង់ព័ត៌មានតម្លៃសត្វ សាច់ និងផលិតផលសត្វប្រចាំខែមិថុនា ឆ្នាំ២០២០ (ឧបសម្ព័ន្ធទី២)
- ស្រង់ព័ត៌មានតម្លៃចំណីសត្វ និងវត្ថុធាតុដើមផ្សំចំណីសត្វ (ឧបសម្ព័ន្ធទី៣)។

### ២-ការងារចិញ្ចឹមសត្វ

- បានធ្វើការណែនាំដល់កសិករឱ្យចេះធ្វើការជ្រើសរើសពូជសត្វល្អៗមកចិញ្ចឹម
- បានជំរុញ និងអប់រំប្រជាកសិករចិញ្ចឹមគោទឹកដោះនៅរាជធានីភ្នំពេញ។



Hr

**៣-ការងារកែលម្អពូជ៖** ប្រជាកសិករមានការយល់ដឹងច្រើនលើការកែលម្អពូជគោ ក្របី ជ្រូក និងបក្សី ជាពិសេសការបង្កាត់ពូជដោយសិប្បនិម្មិត (ឧបសម្ព័ន្ធទី៤)។

**៤- ការងារដំណាំចំណីសត្វ៖** នៅតាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់ប្រជាកសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។ (ឧបសម្ព័ន្ធទី៥)។

**៥. ការងាររបស់ការិយាល័យចំណុះ**

**៥.១. ការិយាល័យអភិវឌ្ឍន៍ការចិញ្ចឹមសត្វ** (ឧបសម្ព័ន្ធទី៦ ,៧)

- ចូលរួមសាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
- ចុះអនុវត្តការងារអនុកម្មវិធីនៅខេត្តត្បូងឃ្មុំ ក្រចេះ កំពង់ចាម និងខេត្តកំពង់ធំ។

**៥.២. ការិយាល័យគ្រប់គ្រងផលិតកម្មចំណីសត្វ**

- ចុះយកវត្ថុវិភាគចំណីផ្អែ ឆ្នា ចំនួន០៥មុខ នៅក្រុមហ៊ុន អ៊ីអន
- ចុះអនុវត្តការងារអនុកម្មវិធីនៅខេត្តក្រចេះ ស្ទឹងត្រែង ព្រៃវែង ស្វាយរៀង តាកែវ កំពង់ចាម និងខេត្តត្បូងឃ្មុំ។

**៥.៣. ការិយាល័យពូជសត្វ និងសេនេទិកសត្វ**

- បើកវគ្គបណ្តុះបណ្តាលស្តីពីការជំរុញសមត្ថភាពមន្ត្រីលើបច្ចេកទេសបង្កាត់សិប្បនិម្មិតគោនៅខេត្តកំពង់ចាម
- បន្តចុះអនុវត្តការបង្កាត់ពូជគោ ជ្រូកដោយសិប្បនិម្មិត
- ចូលរួមសាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
- ចុះអនុវត្តការងារអនុកម្មវិធីនៅខេត្តកំពង់ចាម ព្រះវិហារ សៀមរាប និងខេត្តកំពង់ស្ពឺ។

**៥.៤. ការិយាល័យគ្រប់គ្រងកាកសំណល់សត្វ**

- ត្រៀមរៀបចំការប្រជុំផ្សព្វផ្សាយដល់កសិករស្តីពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឡជីវឧស្ម័ន
- ចុះពិនិត្យនិងជួសជុលឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង
- អមដំណើរប្រតិភូ ADB ចុះវាយតម្លៃការសាងសង់ឡជីវឧស្ម័ន នៅខេត្តកំពង់ចាម និងខេត្តតាកែវ
- ចុះពិនិត្យ និងវាយតម្លៃការគ្រប់គ្រងកាកសំណល់សត្វ នៅខេត្តតាកែវ ព្រះវិហារ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

**៥.៥. ការិយាល័យគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ**

- រៀបចំសិក្ខាសាលាស្តីពីការជំរុញការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ស្របតាមប្រកាសលេខ៥៤៩ ប្រក.កសក នៅខេត្តសៀមរាប កំពង់ចាម បាត់ដំបង និងខេត្តកំពង់ឆ្នាំង
- ចុះពិនិត្យ និងវាយតម្លៃសំណើសុំបើកកសិដ្ឋានចិញ្ចឹមមាន់សាច់ មាន់ពូជ មាន់ផ្តល់ស៊ុត ជ្រូកសាច់ ជ្រូកពូជ គោបំប៉ន ខ្នាតធំ មធ្យម និងតូច បានចំនួន២៥កសិដ្ឋាន
- ចុះអនុវត្តការងារអនុកម្មវិធីនៅខេត្តបាត់ដំបង និងខេត្តព្រះវិហារ
- ចូលរួមសាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិននៅខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ
- រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសសាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ ព្រះវិហារ និងខេត្តត្បូងឃ្មុំ។



Ub

៥.៦. ការិយាល័យអត្តសញ្ញាណកម្មសត្វ

- ចុះអនុវត្តការងារអនុកម្មវិធីនៅខេត្តត្បូងឃ្មុំ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពត តាកែវ និងខេត្តត្បូងឃ្មុំ
- ចូលរួមសាងសង់ឡជីវឧស្ម័នក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ។

III. ការងារវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

១-ការិយាល័យអេពីដេមីសាស្ត្រ និងវិភាគព័ត៌មាន

ការតាមដានជំងឺសត្វ

- ចុះអង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺផ្តាសាយបក្សីនៅតាមទីផ្សារលក់បក្សីរស់នៅខេត្តកំពត កណ្តាល និងខេត្តស្វាយរៀង ដោយសហការជាមួយ NIPH, CDC
- ចុះអង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺផ្តាសាយបក្សីនៅតាមទីផ្សារលក់បក្សីរស់នៅខេត្តព្រៃវែង កណ្តាល តាកែវ និងរាជធានីភ្នំពេញ ដោយសហការជាមួយ FAO, IPC
- ចុះអង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺផ្តាសាយបក្សីនៅតាមទីផ្សារលក់បក្សីរស់នៅខេត្តកំពត កំពង់ចាម ស្វាយរៀង មណ្ឌលគិរី សៀមរាប និងខេត្តកំពង់ធំ ដោយសហការជាមួយ FAO, NAHPRI
- ចុះអង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺប៉េស្តជ្រូកអាហ្វ្រិក និងជំងឺជ្រូកត្រចៀកខៀវ
- សហការជាមួយគម្រោង Pigflu-Cam+ ចុះយកសំណាកពីសត្វជ្រូក-គោ នៅតាមបណ្តារាជធានី ខេត្តចំនួន០៤គឺ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ និងរាជធានីភ្នំពេញ ក្នុងគោលបំណងអង្កេតតាមដានរកមើលវត្តមានជំងឺផ្តាសាយជ្រូក
- សហការជាមួយគម្រោង MORU ចុះយកសំណាកពីសត្វជ្រូក-គោ នៅតាមបណ្តារាជធានីខេត្តចំនួន០៧គឺ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ ព្រៃវែង កំពង់ចាម បាត់ដំបង និងខេត្តសៀមរាប។

**ជំងឺអុតក្តាមៈ** មានផ្ទុះសរុបចំនួន៤០កន្លែង ក្នុងនោះ០៨កន្លែងនៅខេត្តស្វាយរៀង (ស្រុកចន្ទ្រា កំពង់រោទិ៍ ស្វាយជ្រំ រមាសហែក រំដួល ស្វាយទាប ស្វាយរៀង និងក្រុងបាវិត) ០៣កន្លែងនៅខេត្តកណ្តាល (ស្រុកស្អាង និងស្រុកកណ្តាលស្ទឹង) ០៥កន្លែងនៅខេត្តកំពង់ឆ្នាំង (ស្រុកកំពង់ត្រឡាច បរិបូណ៌ សាមគ្គីមានជ័យ និងស្រុកទឹកផុស) ១១កន្លែងនៅខេត្តកំពង់ស្ពឺ (ស្រុកគងពិសី ឱរ៉ាល់ ភ្នំស្រួច សំរោងទង បរសេដ្ឋ ថ្ពង និងស្រុកឧដុង្គ) ០១កន្លែងនៅ ខេត្តកំពត (ស្រុកបន្ទាយមាស) ០៤កន្លែងនៅខេត្តព្រៃវែង (ស្រុកកំចាយមារ កំពង់ត្របែក និងស្រុកស្វាយអន្ទរ) ០៤កន្លែងនៅខេត្តរតនគិរី (ស្រុកកូនមុំ អូរយ៉ាដាវ វ៉ឺនសៃ និងលំផាត់) និង០៤កន្លែងនៅខេត្តសៀមរាប (ស្រុកអង្គរជុំ បន្ទាយស្រី ជីក្រែង និងប្រាសាទបាគង) បណ្តាលឱ្យគោ ក្របីឈឺសរុបចំនួន៧ ៦០២ក្បាល និងងាប់គោ៦៩ក្បាល។

**ជំងឺសារទឹកៈ** មានផ្ទុះសរុបចំនួន០៣កន្លែង ក្នុងនោះ០១កន្លែងនៅក្នុងខេត្តកំពង់ឆ្នាំង (ស្រុកសាមគ្គីមានជ័យ) និង០២ កន្លែងនៅក្នុងខេត្តសៀមរាប (ស្រុកប្រាសាទបាគង និងស្រីស្នំ) បណ្តាលឲ្យគោក្របីឈឺសរុបចំនួន៧០ក្បាល និងងាប់១១ក្បាល។

**ជំងឺបូសខ្យល់ៈ** មានផ្ទុះសរុបចំនួន០១កន្លែងនៅក្នុងខេត្តព្រៃវែង (ស្រុកព្រះស្តេច) បណ្តាលឲ្យសត្វឈឺសរុបចំនួន៤៤ក្បាល។

**ជំងឺញូវកាសៈ** មានផ្ទុះសរុបចំនួន០១កន្លែងនៅខេត្តសៀមរាប (ស្រុកពួក ឃុំកែវពណ៌ ភូមិថ្មី) បណ្តាលឲ្យមាន់ឈឺសរុបចំនួន១៤៩ក្បាល ងាប់៩៩ក្បាល។

**ការស្រាវជ្រាវ បញ្ចូលទិន្នន័យ និងការធ្វើរបាយការណ៍**

- ទំនាក់ទំនងជាមួយមន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាល តាមបណ្តាខេត្តនានាពីស្ថានភាពជំងឺឆ្លងសត្វ
- ស្រាវជ្រាវឯកសារស្តីពីរោគរាតត្បាតសាស្ត្រសម្រាប់បណ្តុះបណ្តាលបសុពេទ្យស្រុក និងខេត្ត
- ចុះបង្ហាញពីរបៀបយកវត្ថុវិភាគ និងរបៀបស្រង់របាយការណ៍ជំងឺសត្វនៅតាមបណ្តារាជធានី ខេត្ត

- ចុះអង្កេតស្រាវជ្រាវ តាមដានឃ្លាំមើលពីជំងឺផ្តាសាយបក្សី និងជំងឺទូទៅក្នុងរាជធានី ខេត្ត
- ពិនិត្យផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពជំងឺផ្តាសាយបក្សីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំរបាយការណ៍ជាប្រចាំស្តីពីស្ថានភាពជំងឺសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រាយការណ៍ព័ត៌មានពីស្ថានភាពជំងឺឆ្លងសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្នុងប្រព័ន្ធព័ត៌មានសុខភាពសត្វរបស់អាស៊ាន និងទៅអង្គការសុខភាពសត្វពិភពលោក (OIE)។

**២-ការងារមន្ទីរពិសោធន៍**

**២.១-មន្ទីរពិសោធន៍ប៉ារ៉ាស៊ីតសាស្ត្រ:** ពិនិត្យ និងវិភាគបានចំនួន២ ៧៩៨វត្ថុវិភាគ។ លទ្ធផល: វត្ថុវិភាគចំនួន០៥ វិជ្ជមាន Trypanosomes។

**២.២-មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ និងមីកូសាស្ត្រ:** ពិនិត្យ និងវិភាគបានចំនួន២ ៩៤០វត្ថុវិភាគ។ លទ្ធផល: វត្ថុវិភាគចំនួន២៤ វិជ្ជមាន E.Coli និងវត្ថុវិភាគចំនួន១៧ វិជ្ជមាន Salmonella។

**២.៣-មន្ទីរពិសោធន៍វីរុសសាស្ត្រ:** ពិនិត្យ និងវិភាគបានចំនួន២ ៣៤៣វត្ថុវិភាគ។ លទ្ធផល: វត្ថុវិភាគចំនួន០៤វិជ្ជមាន NDV វត្ថុវិភាគចំនួន០២ វិជ្ជមាន FMD និងវត្ថុវិភាគចំនួន០៤ វិជ្ជមាន Antibody FMD។

**២.៤-មន្ទីរពិសោធន៍រោគសាស្ត្រ:** វះពិនិត្យលើសត្វសរុបបានចំនួន២៦៩វត្ថុវិភាគ។

**២.៥-មន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ**

- បាននឹងកំពុងដំណើរការរៀបចំមន្ទីរពិសោធន៍ និងពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការចូលរួមសិក្សាស្តីពីដំណើរការសាកល្បងនៃម៉ាស៊ីន UPLC
- រៀបចំធ្វើបច្ចុប្បន្នភាពស្តង់ដារនីតិប្រតិបត្តិ SOP ជាមួយអ្នកជំនាញការ FAO និង I-TECH
- ចូលរួមចុះធ្វើអង្កេតឃ្លាំមើល និងស្រាវជ្រាវការផ្ទុះជំងឺឆ្លងសត្វនៅតាមរាជធានី ខេត្ត។

**២.៦-មន្ទីរពិសោធន៍គុណភាពចំណីសត្វ**

- ធ្វើការវិភាគលើចំណីឆ្កែ ឆ្មា ជ្រូក មាន់ ទា និងបង្កង បានចំនួន១៧មុខ
- ចុះសិក្សាពីសក្តានុពលភាពដំណាំចំណីសត្វនៅខេត្តតាកែវ
- ចុះរៀបចំទ្រុងពិសោធន៍ ពិនិត្យវាយតំលៃ ជ្រើសរើសលក្ខណៈសម្បត្តិគោពិសោធន៍ក្នុងគម្រោងស្រាវជ្រាវប្រសិទ្ធភាពនៃការបន្ថែមចំណីគោកែច្នៃតាមបែបធម្មជាតិដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកនៅស្ថានីយ៍-ពិសោធន៍ពូជគោភ្នំតាម៉ៅ
- ធ្វើការពិសោធន៍លើចំណីគោនៅស្ថានីយ៍ពិសោធន៍ពូជគោភ្នំតាម៉ៅ ខេត្តតាកែវ
- រៀបចំឯកសារសិក្សាស្រាវជ្រាវដំណាំចំណីសត្វ និងកែតម្រូវព្រឹត្តិប័ត្រព័ត៌មាន
- រៀបចំធ្វើបច្ចុប្បន្នភាពស្តង់ដារនីតិប្រតិបត្តិ SOP ជាមួយអ្នកជំនាញការ FAO និង I-TECH
- សិក្សាស្រាវជ្រាវឯកសារចំណីសត្វ
- ចូលរួមចុះធ្វើអង្កេតឃ្លាំមើល និងស្រាវជ្រាវការផ្ទុះជំងឺឆ្លងសត្វនៅតាមបណ្តារាជធានី ខេត្ត។

**២.៧-មន្ទីរពិសោធន៍សេនេទិកពូជសត្វ**

- រៀបចំសម្ភារបង្កាត់ និងសម្ភារកែច្នៃទឹកមេជីវិតបង្កក សម្រាប់ត្រៀមអនុវត្តការងារ
- ចុះប្រមូលទឹកមេជីវិត និងកែច្នៃទឹកមេជីវិតគោបង្កកសរុបបានចំនួន៥២៩ដើម នៅខេត្តតាកែវ
- ចុះសិក្សាប្រមូលព័ត៌មានស្ថានភាពចិញ្ចឹមគោ ណែនាំបង្ហាញពូជគោបាថ្មី និងសិក្សាចំណង់ចំណូលប្រភេទគោបា ដើម្បីដំណើរការបង្កាត់សិប្បនិម្មិតគោ នៅក្នុងភូមិ-ឃុំគោលដៅ ដូចជាក្នុងឃុំកោះរកា កោះទន្ទឹម និងកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដោយបានចាក់អ័រម៉ូនលើមេគោបានចំនួន២៩ក្បាល និងបង្កាត់សិប្បនិម្មិតបានចំនួន១៨ក្បាល ហើយសល់១២ក្បាលទៀតដែលត្រូវចាក់អ័រម៉ូនជាលើកទី២ បន្តទៀត និងរង់ចាំការបង្កាត់បន្ថែម
- ផ្សព្វផ្សាយដល់ខេត្តដែលខ្វះខាតទឹកមេជីវិតគោ ដើម្បីយកទៅអនុវត្តនិងបណ្តាខេត្តផ្សេងៗទៀត



ll

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីស្តីពីការបង្កាត់សិប្បនិម្មិតគោ និងការកែច្នៃទឹកមេជីវិតគោបង្កាត់សម្រាប់ឆ្នាំ២០២០
- ចូលរួមចុះធ្វើអង្កេតឃ្លាំមើល និងស្រាវជ្រាវការផ្ទុះជំងឺឆ្លងសត្វនៅតាមរាជធានី-ខេត្ត។

**២.៨-មន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ**

- ចុះធ្វើអង្កេតតាមដាន និងយកវត្ថុវិភាគសាច់សត្វនៅតាមទីផ្សារ ឬសត្តឃាតដ្ឋាន ដើម្បីធ្វើតេស្តរកវត្តមានកាកសំណល់បសុឱសថនៅតាមបណ្តារាជធានី-ខេត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលដោយអនុវត្តន៍តេស្ត Charm II (screening Test) វិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិកនៅក្នុងសាច់ ទឹកដោះ និងស៊ុត ក្រោមគម្រោង KAM5004-ការពង្រឹងសមត្ថភាពជាតិដើម្បីសុវត្ថិភាពចំណីអាហារនៃទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ (IAEA)
- ចូលរួមបណ្តុះបណ្តាល UPLC វិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិច និងពពួកបេតាអាហ្គោនីសនៅក្នុងសត្វ និងសាច់សត្វ
- អនុវត្តតេស្ត UPLC and Charm II (Screening Test) វិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិចនៅក្នុងសាច់ជ្រូក និងសាច់គោដែលលក់តាមផ្សារនៅតាបណ្តារាជធានី ខេត្ត
- រៀបចំធ្វើបច្ចុប្បន្នភាពស្តង់ដារនីតិប្រតិបត្តិ SOP
- សិក្សាស្រាវជ្រាវបន្ថែមតាមគេហទំព័រស្តីពីអត្ថប្រយោជន៍ និងការប្រើប្រាស់ម៉ាស៊ីន UPLC
- រៀបចំបញ្ជីសំណួរសម្រាប់ធ្វើអង្កេតលើការប្រើប្រាស់ឱសថ និងរៀបចំបង្កើតបញ្ជីសំណួរសម្រាប់យកវត្ថុវិភាគនៅតាមសត្តឃាតដ្ឋានដើម្បីវិភាគមើលកាកសំណល់បសុឱសថនៅក្នុងសត្វ និងផលិតផលសាច់សត្វ
- រៀបចំឯកសារស្តីពីការប្រើប្រាស់ និងអត្ថប្រយោជន៍ម៉ាស៊ីន UPLC វិភាគរកកាកសំណល់បសុឱសថ នៅក្នុងសត្វ និងផលិតផលសាច់សត្វ សម្រាប់បណ្តុះបណ្តាលដល់មន្ត្រីបសុពេទ្យ
- រៀបចំផែនការសកម្មភាពគម្រោងថវិកាស្រាវជ្រាវបសុឱសថ និងកាកសំណល់បសុឱសថ
- ចូលរួមចុះធ្វើអង្កេតស្តីពីការប្រើប្រាស់ឱសថរបស់ភ្នាក់ងារសុខភាពសត្វភូមិនៅតាមរាជធានី ខេត្ត។

**៣-ស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល**

**ស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅ**

គោសរុបមានចំនួន១០៦ក្បាល (ក្នុងនោះមេគោប្រាម៉ាន់ឈឺងាប់០១ក្បាល)។ កូនកើត០១ក្បាល (ញីប្រាម៉ាន់)។

**ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន**

ជ្រូកសរុបចំនួន១២២ក្បាល (ជ្រូកបា មេទំនេរ ផ្តាច់ដោះ មេធើម មេបំបៅដោះកូន និងកូនអាយុ១-៦១) ក្នុងនោះជ្រូកលក់បានចំនួន៥០ក្បាល និងជ្រូកងាប់ចំនួន០១ក្បាល (គិតត្រឹមខែមីនា ឆ្នាំ២០២០)។ ចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ស្ថានីយ៍ចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន ត្រូវបានបិទទាំងស្រុង ដោយសារមានការឆ្លងរាលដាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក។

**៤-ការងារតាមដាន និងទប់ស្កាត់ជំងឺផ្តាសាយបក្សី**

- បន្តទទួលព័ត៌មានជំងឺផ្តាសាយបក្សី ឬជំងឺសត្វផ្សេងៗទៀត តាមរយៈទូរស័ព្ទ Hotline របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- សហការជាមួយអង្គការ FAO និង I-TECH ដើម្បីរៀបចំធ្វើរោគវិនិច្ឆ័យជំងឺសត្វ

- ចូលរួមប្រជុំផ្សព្វផ្សាយលទ្ធផលការអង្កេត តាមដាន ឃ្លាំមើលជំងឺផ្តាសាយបក្សី នៅតាមទីផ្សារលក់បក្សីរស់នៅខេត្តសៀមរាប កំពង់ធំ និងខេត្តមណ្ឌលគិរី ដែលមានអាជីវករលក់មាន់ ដឹកជញ្ជូន អ្នកចិញ្ចឹមសរុបចំនួន១២៦នាក់ ស្រី៤២នាក់ និងមន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត។

**៥-ការងារផ្សេងៗ**

-ចុះធ្វើការអង្កេតតាមដានស្រាវជ្រាវ យកវត្ថុវិភាគ និងឃ្លាំមើលលើជំងឺសត្វនៅរាជធានី-ខេត្ត ក្នុងករណីសង្ស័យមានផ្ទុះជំងឺឆ្លងសត្វ

-ចុះយកវត្ថុវិភាគនៅតាមទីផ្សារលក់បក្សីរស់ ដោយសហការជាមួយនាយកដ្ឋានប្រយុទ្ធប្រឆាំងជំងឺឆ្លងក្នុងគម្រោង CDC នៅខេត្តស្វាយរៀង កំពត កណ្តាល និងខេត្តព្រៃវែង

-ចុះប្រមូលវត្ថុវិភាគសម្រាប់ការធ្វើអង្កេតតាមដានជំងឺឆ្លងសត្វ និងប្រមូលព័ត៌មាននានាក្នុងគម្រោង Concerning the Research Cooperation on Research in the Field of Surveillance, Diagnosis and Control of Transboundary Animal Diseases នៅតាមទីសត្តឃាដចំនួន០៥កន្លែងនៅក្នុងរាជធានីភ្នំពេញ

-ចុះសហការជាមួយរដ្ឋបាលព្រៃឈើលើការងារស្រាវជ្រាវពីកត្តាហានិភ័យនៃការប្រឈមនឹងជំងឺឆ្លង និងយកវត្ថុវិភាគពីសត្វព្រៃនៅខេត្តត្បូងឃ្មុំ ក្រចេះ និងខេត្តស្ទឹងត្រែង

-សហការជាមួយអ្នកបច្ចេកទេសរបស់អង្គការ FAO និងI-TECH ដែលមកជួយធ្វើការលើជំងឺផ្តាសាយបក្សី និងការធ្វើរោគវិនិច្ឆ័យជំងឺសត្វ

-ចុះសហការជាមួយវិទ្យាស្ថានជាតិប៉ាស្ទ័រលើការងារស្រាវជ្រាវពីកត្តាហានិភ័យនៃការប្រឈមនឹងជំងឺឆ្លង

-ចុះរៀបចំបទអន្តរាគមន៍ដល់អាជីវករលក់សាច់ជ្រូក (ការលើកកំពស់ការអនុវត្តន៍អនាម័យល្អសម្រាប់សាច់ជ្រូកមានសុវត្ថិភាពតាមទីផ្សារ) ក្នុងគម្រោង Safe Food Fair Food-SFFF, International Livestock Research Institute (ILRI) នៅកម្ពុជា ដោយសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្តចំនួន០៦រួមមាន: ខេត្តតាកែវ កំពត កំពង់ស្ពឺ កំពង់ចាម សៀមរាប និងរាជធានីភ្នំពេញ។

**IV. ការងារនាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល**

**១-ការងារត្រួតពិនិត្យអនាម័យបសុព្យាបាល**

- **ការត្រួតពិនិត្យចលនាសត្វ និងផលិតផលសត្វក្នុងប្រទេស៖**
  - ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបបានចំនួន១២២ករណី ក្នុងនោះបង្ក្រាប២៩ករណីរួមមាន: មាន់រស់០៩ករណី ទារស់០១ករណី ជ្រូករស់១៣ករណី ក្របីរស់០២ករណី គោរស់០២ករណី ស៊ុតទា០១ករណី និងប្រហិត០១ករណី (មិនមានលិខិតអនុញ្ញាតត្រឹមត្រូវ) និងត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ៩៣ករណីរួមមាន: ការដឹកជញ្ជូនគោក្របីរស់៥៣ករណី ការដឹកជញ្ជូនជ្រូករស់៣៧ករណី និងការដឹកជញ្ជូនមាន់រស់០៣ករណី។
- **ការត្រួតពិនិត្យចលនាសត្វ និងផលិតផលសត្វនាំចេញ៖** ចុះធ្វើការត្រួតពិនិត្យការដឹកជញ្ជូនសត្វ និងផលិតផលសត្វ នៅក្រុមហ៊ុនបានចំនួន១៤ក្រុមហ៊ុន។
- **ការស្នើសុំគោលការណ៍សត្វ និងផលិតផលសត្វនាំឆ្លងកាត់៖** ចុះធ្វើការត្រួតពិនិត្យការដឹកជញ្ជូនសត្វ និងផលិតផលសត្វនៅក្រុមហ៊ុនចំនួន១២ក្រុមហ៊ុន។



ፉ

**២-ការងារគ្រប់គ្រងផលិតផលបសុព្យាបាល**

- ចុះត្រួតពិនិត្យកន្លែងលក់ផលិតផលបសុព្យាបាលនៅតាមបណ្ដាខេត្ត រាជធានីសរុបបានចំនួន១៥ រួមមានៈ ខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង ឧត្ដរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន តាកែវ កែប ក្រចេះ ស្ទឹងត្រែង និងខេត្តកំពត ស្មើនឹង១២៨កន្លែង ដែលមានសិក្ខាកាមចូលរួមចំនួន ៨៣នាក់ (ស្រី១៧នាក់)
- បានទទួលតារាងបច្ចុប្បន្នភាពកន្លែងលក់ផលិតផលបសុព្យាបាលចំនួន០៩ ខេត្ត-រាជធានី ក្នុងនោះមានៈ រាជធានីភ្នំពេញ កំពត កោះកុង កំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងខេត្តបាត់ដំបង
- ក្រុមហ៊ុនចំនួន០២ ស្នើសុំចុះបញ្ជីកាបសុឱសថ១១០មុខ វ៉ាក់សាំង០៥មុខ និងសុំនាំចូលបសុឱសថ១៤៧មុខ វ៉ាក់សាំង១៥មុខ បរិក្ខាបសុពេទ្យ២៧មុខ។

**៣. ការងារអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺសត្វ** (ឧបសម្ព័ន្ធទី៩,១០,១១,១២)

- ចុះអន្ដរាគមន៍ទប់ស្កាត់ការឆ្លងរាលដាលជំងឺអុតក្ដាម និងចែកបសុឱសថ និងសម្ភារបរិក្ខាបសុពេទ្យមួយ ចំនួនដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តព្រៃវែង ស្វាយរៀង និងខេត្តកំពង់ស្ពឺ
- ចុះជួយអន្ដរាគមន៍ត្រួតពិនិត្យស្ថានភាពជំងឺសត្វ និងធ្វើជីវសុវត្ថិភាពនៅតំបន់មានកើតជំងឺលើសត្វមាន់ក្នុងភូមិព្រៃតាហ៊ូ សង្កាត់ព្រៃតាហ៊ូ និងភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងចែកសម្ភារបរិក្ខាបសុពេទ្យមួយចំនួនដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត
- ចុះយុទ្ធនាការចាក់ថ្នាំការពារជំងឺឆ្លងសត្វនៅខេត្តពោធិ៍សាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ តាកែវ ឧត្ដរមានជ័យ និងខេត្តត្បូងឃ្មុំ មានកសិករចូលរួមចំនួន៦៤៦នាក់ (ស្រី២២៨នាក់)
- ចុះអន្ដរាគមន៍ទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វនៅខេត្តព្រៃវែង សៀមរាប តាកែវ និងខេត្តស្វាយរៀង កសិករចូលរួមមានចំនួន ៣៧៥ នាក់ (ស្រី១៤៦នាក់)
- ចុះរៀបចំកម្មវិធីបង្កើនការយល់ដឹងអំពីការទប់ស្កាត់ការឆ្លងរាលដាលជំងឺប៉េស្ដជ្រូកអាហ្វ្រិកដល់កសិករ និងការធ្វើជីវសុវត្ថិភាពនៅខេត្តសៀមរាបដែលមានកសិករចូលរួមមានចំនួន២៤២នាក់ (ស្រី១៦៨នាក់)
- ចុះបាញ់ថ្នាំសម្លាប់មេរោគនៅបរិវេណក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងរដ្ឋបាលព្រៃឈើ
- ចុះអង្កេត តាមដាន ក្រោយការចាក់ថ្នាំការពារជំងឺឆ្លងសត្វនៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។

**៤- ការងារគ្រប់គ្រងមន្ទីរព្យាបាលសត្វ**

- ធ្វើបច្ចុប្បន្នភាពគ្លីនិកព្យាបាលសត្វនៅតាមបណ្ដារាជធានី-ខេត្តសរុបបានចំនួន៥០កន្លែង ក្នុងនោះរាជធានីភ្នំពេញ ២៥កន្លែង កណ្ដាល០២កន្លែង បាត់ដំបង០៣កន្លែង បន្ទាយមានជ័យ០២កន្លែង សៀមរាប ០៥កន្លែង កំពង់ចាម ០៤កន្លែង ក្រចេះ០៣កន្លែង ស្ទឹងត្រែង០២កន្លែង កំពត០១កន្លែង ព្រះសីហនុ០២ និងខេត្តកំពង់ស្ពឺ០១កន្លែង
- ចុះត្រួតពិនិត្យការប្រើប្រាស់បសុឱសថនៅខេត្តព្រះវិហារ ឧត្ដរមានជ័យ កំពង់ធំ សៀមរាប ពោធិ៍សាត់ បាត់ដំបង កំពង់ចាម ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង កោះកុង និងខេត្តរតនគិរី ដោយអ្នកចូលរួមសរុបមានចំនួន២០០នាក់។

**៥- ការងារសត្តឃាតដ្ឋាន និងកែច្នៃ**

- ចុះត្រួតពិនិត្យសំណើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វសម្រាប់ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមសរុបចំនួន០៦នាក់ (ស្រី០១នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសលើទីតាំងស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋានជ្រូកប្រភេទ "ខ" នៅខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមសរុបចំនួន២០នាក់ (ស្រី០៣នាក់)



16

- ចុះត្រួតពិនិត្យបច្ចេកទេសលើទីតាំងស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋានគោ ក្របី ប្រភេទ "ខ" នៅខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមសរុបចំនួន២០នាក់ (ស្រី០៣នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសលើទីតាំងស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋាន គោ ក្របី ជ្រូក ប្រភេទ "ខ" នៅខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមសរុបចំនួន៤៥នាក់ (ស្រី០៦នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសស្នើសុំបញ្ឈប់ការប្រកបអាជីវកម្មសត្តឃាតដ្ឋាននៅខេត្តកណ្តាល ដោយមានអ្នកចូលរួមសរុបចំនួន១៥នាក់ (ស្រី០២នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋាននៅខេត្តកំពង់ឆ្នាំង បាត់ដំបង និងខេត្តសៀមរាប ដោយមានអ្នកចូលរួមសរុបចំនួន៤១នាក់
- ចុះត្រួតពិនិត្យបច្ចេកទេសស្នើសុំបង្កើតសត្តឃាតដ្ឋាន ជ្រូក គោ-ក្របី ប្រភេទ "ខ" នៅរាជធានីភ្នំពេញ និងខេត្តកំពត ដោយមានអ្នកចូលរួមសរុបចំនួន១១នាក់ (ស្រី៣នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសស្នើសុំបង្កើតសត្តឃាតដ្ឋានបក្សី "ខ" នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមសរុបចំនួន០៤នាក់
- ចុះបង្កើនការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសនៅតាមបណ្តារាជធានី ខេត្តចំនួន ១៦ រួមមានៈ រាជធានីភ្នំពេញ ព្រៃវែង បាត់ដំបង កំពត បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង ស្វាយរៀង កំពង់ស្ពឺ ព្រះសីហនុ ឧត្តរមានជ័យ កណ្តាល កែប សៀមរាប រតនគិរី និងខេត្តកោះកុង ដោយមានអ្នកចូលរួមសរុបចំនួន២៤១នាក់ (ស្រី៤៦នាក់) (ឧបសម្ព័ន្ធទី១៣,១៤)
- ចុះត្រួតពិនិត្យ និងវាយតម្លៃសត្តឃាតដ្ឋានគំរូនៅរាជធានីភ្នំពេញដោយមានអ្នកចូលរួមសរុបចំនួន១៦នាក់ (ស្រី០៤នាក់)។

**៦-ការងារអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ុញូស**

- ចុះទប់ស្កាត់ការឆ្លងរាលដាលជំងឺអុតក្តាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង
- ចុះពង្រឹងការអនុវត្តអនាម័យសត្វ សាច់ និងផលិតផលសត្វដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងពីសត្វមកមនុស្ស និងពីមនុស្សមកសត្វ នៅតាមបណ្តាខេត្តចំនួន១៧ រួមមានៈ ខេត្តបាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រៃវែង ស្វាយរៀង កែប តាកែវ កំពត កំពង់ស្ពឺ ព្រះសីហនុ កំពង់ចាម ត្បូងឃ្មុំ រតនគិរី កំពង់ឆ្នាំង មណ្ឌលគិរី និងខេត្តក្រចេះ។

**៧-ការអនុវត្តវិធានបសុពេទ្យ**

**ខេត្តកំពត-**

- បាញ់ថ្នាំសម្លាប់មេរោគនៅសត្តឃាតដ្ឋានចំនួន១១៤លើក កន្លែងចិញ្ចឹមគោ១២លើក កន្លែងចិញ្ចឹមជ្រូក៩៦លើក កន្លែងចិញ្ចឹមមាន់៩១លើក កន្លែងចិញ្ចឹមទា៤៥លើក កន្លែងពិឃាតមាន់១៦លើក កន្លែងលក់មាន់៣១លើក ទ្រុងចិញ្ចឹម២៩លើក បរិវេណភូមិ០៧លើក និងកន្លែងផ្ទុះជំងឺ០២លើក
- ចុះសហការរឹបអូសផលិតផលខូចគុណភាពរួមមានៈ គ្រឿងក្នុងជ្រូក (ថ្លើម សួត និងពោះវៀន) ចំនួន៦២,៧ គ.ក្រ ផ្ទាំងសាច់ជ្រូក២៩គ.ក្រ និងផ្ទាំងសាច់គោ៦គ.ក្រ។ (ឧបសម្ព័ន្ធទី១៥)

**ខេត្តព្រៃវែង**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ១០៣លើក កន្លែងចិញ្ចឹមក្របី០៥លើក កន្លែងចិញ្ចឹមជ្រូក ១៩៨លើក កន្លែងចិញ្ចឹមមាន់១ ៧៩៥លើក កន្លែងចិញ្ចឹមទា៧៧លើក កន្លែងពិឃាតមាន់១៥លើក ទ្រុងចិញ្ចឹម១ ២០៣លើក និងសត្តឃាតដ្ឋាន១៣៤លើក។

**ខេត្តតាកែវ**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ១ ៦២១លើក កន្លែងចិញ្ចឹមក្របី៨៦លើក កន្លែងចិញ្ចឹមជ្រូក ១ ៣៧៣លើក កន្លែងចិញ្ចឹមមាន់១២ ៨៦៧លើក កន្លែងចិញ្ចឹមទា៤៩៦លើក កន្លែងពិឃាតមាន់៣៧លើក កន្លែងលក់មាន់២៧៧លើក ទ្រុងចិញ្ចឹមសត្វ៣៣ ១៦៤លើក បរិវេណភូមិ៥ ១៨០លើក សត្តឃាតដ្ឋាន ៣១លើក ផ្លូវជាតិ០១លើក និងកន្លែងផ្ទុះជំងឺ០១លើក។

**ខេត្តបាត់ដំបង**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ១៩៩លើក កន្លែងចិញ្ចឹមក្របី៦លើក កន្លែងចិញ្ចឹមជ្រូក ៦៨៥លើក កន្លែងចិញ្ចឹមមាន់៦០៣លើក កន្លែងចិញ្ចឹមទា៣៧៤លើក កន្លែងពិឃាតមាន់៥៧លើក កន្លែងលក់មាន់៨៩លើក ទ្រុងចិញ្ចឹម៥៩៤លើក បិរវេណភូមិ១៣២លើក សត្តឃាតដ្ឋាន២៩២លើក ផ្លូវជាតិ០៧ លើក និងកន្លែងផ្ទុះជំងឺ០៥លើក។

**ខេត្តកំពង់ស្ពឺ**-

- ចុះបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ៩៣លើក កន្លែងចិញ្ចឹមជ្រូក១៨៥លើក កន្លែងចិញ្ចឹមមាន់ ១៨៣លើក ទ្រុងចិញ្ចឹម៤៤១លើក និងសត្តឃាតដ្ឋាន២២៣លើក
- ចុះធ្វើការណែនាំនិងធ្វើកំណត់ហេតុដកហូតសាច់ជ្រូកខូចគុណភាពកប់ចោលនៅផ្សារបាត់ដឹង។

**ខេត្តស្វាយរៀង**-ចុះបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ២៦៨លើក កន្លែងចិញ្ចឹមក្របី១៣១លើក កន្លែងចិញ្ចឹមជ្រូក៣២៩លើក កន្លែងចិញ្ចឹមមាន់៣៨៥លើក កន្លែងចិញ្ចឹមទា៥៧លើក កន្លែងពិឃាតមាន់៣៨លើក កន្លែងលក់មាន់៨៥លើក ទ្រុងចិញ្ចឹម៣៧១លើក បរិវេណភូមិ៦៧លើក សត្តឃាតដ្ឋាន២១៩លើក ផ្លូវជាតិ ១១០លើក និងកន្លែងផ្ទុះជំងឺ១០លើក។

**ខេត្តកំពង់ឆ្នាំង**-

- បាញ់ថ្នាំសម្លាប់រោគនៅកន្លែងចិញ្ចឹមគោ២៨៩លើក កន្លែងចិញ្ចឹមជ្រូក២២០លើក កន្លែងចិញ្ចឹមមាន់៦២៦ លើក កន្លែងចិញ្ចឹមទា៤៤លើក ទ្រុងចិញ្ចឹម៣៦៩លើក សត្តឃាតដ្ឋាន១២០លើក និងកន្លែងផ្ទុះជំងឺ១៧០លើក
- ចុះឃាត់ចាប់រថយន្តដឹកជ្រូកខុសច្បាប់ពីប្រទេសថៃបាន០១ករណី។

**ខេត្តប៉ៃលិន**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ៨៤លើក កន្លែងចិញ្ចឹមជ្រូក៨២លើក កន្លែងចិញ្ចឹមមាន់ ៦៤លើក ទ្រុងចិញ្ចឹម៤២លើក បរិវេណភូមិ៣៩លើក និងសត្តឃាតដ្ឋាន៣៦លើក។

**ខេត្តក្រចេះ**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូក៥៤លើក កន្លែងចិញ្ចឹមមាន់៥២លើក កន្លែងចិញ្ចឹមទា ០៨លើក កន្លែងពិឃាតមាន់១៦លើក ទ្រុងចិញ្ចឹម៥១លើក និងសត្តឃាតដ្ឋាន៥៧លើក។

**ខេត្តស្ទឹងត្រែង**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូក១៨៣លើក កន្លែងចិញ្ចឹមមាន់២៤៧លើក កន្លែងចិញ្ចឹមទា៦លើក ទ្រុងចិញ្ចឹម២០៥លើក បរិវេណភូមិ២១២លើក និងសត្តឃាតដ្ឋាន០៦លើក។

**ខេត្តកំពង់ចាម**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ៧៦លើក កន្លែងចិញ្ចឹមក្របី៨២លើក កន្លែងចិញ្ចឹមជ្រូក ៧១លើក កន្លែងចិញ្ចឹមមាន់៣០៤លើក កន្លែងចិញ្ចឹមទា១៧១លើក កន្លែងពិឃាតមាន់៣៥លើក កន្លែងលក់មាន់៣២លើក ទ្រុងចិញ្ចឹម២០លើក បរិវេណភូមិ០១លើក សត្តឃាតដ្ឋាន៣០លើក និងកន្លែងផ្ទុះជំងឺ០៤លើក។

**ខេត្តត្បូងឃ្មុំ**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ៤០៦លើក កន្លែងចិញ្ចឹមក្របី២២៥លើក កន្លែងចិញ្ចឹមជ្រូក៧២៣លើក កន្លែងចិញ្ចឹមមាន់៥៣៦លើក កន្លែងចិញ្ចឹមទា១៨៩លើក កន្លែងពិឃាតមាន់២៥លើក កន្លែងលក់មាន់២៣លើក ទ្រុងចិញ្ចឹម៦៤១លើក និងសត្តឃាតដ្ឋាន១៩០លើក។

**ខេត្តកណ្តាល**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ៤៩លើក កន្លែងចិញ្ចឹមក្របី០២លើក កន្លែងចិញ្ចឹមជ្រូក ២ ២០២លើក កន្លែងចិញ្ចឹមមាន់១ ២៤០លើក កន្លែងចិញ្ចឹមទា៧៨លើក កន្លែងពិឃាតមាន់០៣លើក កន្លែងលក់មាន់៤៤លើក ទ្រុងចិញ្ចឹម៤៥៣លើក បរិវេណភូមិ២៧លើក និងសត្តឃាតដ្ឋាន១៥១។

**ខេត្តកែប**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ១៥លើក កន្លែងចិញ្ចឹមជ្រូក៣៦លើក កន្លែងចិញ្ចឹមមាន់១៥ លើក ទ្រុងចិញ្ចឹម០៨លើក និងសត្តឃាតដ្ឋាន៧០លើក។

**ខេត្តកំពង់ធំ**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ០៥លើក កន្លែងចិញ្ចឹមជ្រូក៩៦លើក កន្លែងចិញ្ចឹមមាន់១៥៣លើកកន្លែងចិញ្ចឹមទា១២៥លើក កន្លែងលក់មាន់០៤លើក ទ្រុងចិញ្ចឹម២៨៣លើក បរិវេណភូមិ២៨លើក សត្តឃាតដ្ឋាន៣៤លើក និងផ្លូវជាតិ០២លើក

- ចុះបង្ក្រាបបទល្មើសអនាម័យសត្វ០១ករណីដោយបានឃាត់រថយន្ត០១គ្រឿងដឹកគ្រឿងក្នុងជ្រូកចំនួន៩២៩គ.ក្រ នៅចំណុចឃុំកកោះ ស្រុកសន្ទុក បំផ្លាញចោលតាមវិធានបសុពេទ្យ។

**ខេត្តកោះកុង**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោ២៧លើក កន្លែងចិញ្ចឹមក្របី១៣លើក កន្លែងចិញ្ចឹមជ្រូក១៨លើក កន្លែងចិញ្ចឹមមាន់៤០លើក កន្លែងចិញ្ចឹមទា០៨លើក កន្លែងពិឃាតមាន់១២លើក កន្លែងលក់មាន់០៦លើក ទ្រុងចិញ្ចឹម១១លើក និងសត្តឃាតដ្ឋាន១៦លើក។

**ខេត្តមណ្ឌលគិរី**-បាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូក១៨លើក កន្លែងចិញ្ចឹមមាន់០៩លើក កន្លែងចិញ្ចឹមទា១៨លើក កន្លែងពិឃាតមាន់០៦លើក ទ្រុងចិញ្ចឹម១២លើក សត្តឃាតដ្ឋាន១២លើក និងកន្លែងផ្ទះជំងឺ០៦លើក។

